ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ៖ ០៩៧/១៩ រឃក.

# របាយការណ៍បូកសរុប
## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខែមេសា និងទិសដៅខែឧសភា ឆ្នាំ២០១៩

## I. ស្ថានភាពទូទៅ

ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាប ជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ និងអង្គភាពពាក់ព័ន្ធនានា រួមទាំងលេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ)។ ក្រោយពីរាជរដ្ឋាភិបាលថៃ បានផ្តល់ភាពស្របច្បាប់ដល់ពលករប្រមាណ ជាងមួយលានប្រាំមួយម៉ឺននាក់ ហើយក៏ដោយ ក៏ការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍មិនប្រក្រតីក៏នៅតែមានដដែល ពលរដ្ឋខ្មែរនៅតែបាន និងកំពុងចូលទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ជាបន្តទៅទៀត ទោះបីត្រូវជួបប្រទះបញ្ហាប្រឈម ហានិភ័យនានា ដូចជា ការបញ្ជូនត្រឡប់មកវិញ ការឃាត់ខ្លួន ការដាក់ទោសទណ្ឌ ពីអាជ្ញាធរប្រទេសថៃ រងការកេងប្រវ័ញ្ច ខាតបង់ប្រាក់កាស និងពេលវេលា ជាដើម។ល។ ប្រជាពលរដ្ឋមួយចំនួន នៅតែចាញ់ឧបាយកលមេខ្យល់បោកប្រាស់ ដែលប្រើរូបភាពជាភ្នាក់ងារមានសមត្ថកិច្ច ផ្តល់ឯកសារក្លែងក្លាយជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ហើយទាមទារកម្រៃខ្ពស់ពីពលករ ឬជាអ្នកជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនទៅរកការងារក្រៅប្រទេស មានប្រាក់ខែច្រើន។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព ដៃគូជាតិ និងអន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

### ក. ការរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការងារបទដ្ឋានច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងឯកសារកិច្ចសហប្រតិបត្តិការកំពុងរៀបចំ និងដំណើរការ

ក.១.១. គោលនយោបាយកំពុងរៀបចំ

- ក្រសួងអប់រំ យុវជន និងកីឡា៖ កំពុងធ្វើសេចក្តីព្រាងគោលនយោបាយ ស្តីពី "កិច្ចការការពារកុមារតាមសាលារៀន"។

ក.១.២.សេចក្តីព្រាងច្បាប់កំពុងរៀបចំ

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងច្បាប់៖
  - ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA)
  - ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

ក.១.៣.សន្ធិសញ្ញាកំពុងរៀបចំ

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

ក.១.៤.អនុស្សរណៈកំពុងរៀបចំ

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រី លើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃប្រទេសម៉ាឡេស៊ី ស្តីពី "ការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី"។

ក.១.៥.បទដ្ឋានគតិយុត្តកំពុងរៀបចំ

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ ធ្វើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "សម្រាប់អនុវត្តលក្ខខណ្ឌការងារកម្មករការងារផ្ទះ"។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ. ការបង្ការ ទប់ស្កាត់

### ខ.១. ការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង

#### ខ.១.១.ការផ្សព្វផ្សាយដោយផ្ទាល់

ខ.១.១.១.ការផ្សព្វផ្សាយតាមរយៈវេទិកា និងកម្មវិធីផ្សេងៗ

នៅក្នុងខែមេសា ឆ្នាំ២០១៩នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន ៦.៥៧១លើក មានអ្នកចូលរួមសរុបចំនួន ២៩៧.៩៥៣នាក់ (បើប្រៀបធៀបនឹងខែមីនា មានចំនួន ២៣៩.៥០៧នាក់ គឺមានការកើនឡើងចំនួន ៥៨.៤៤៦នាក់ ស្មើនឹង ២៤,៤០%) ក្នុងនោះស្ត្រីចំនួន ១៦៦.៧២៩នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

## តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១៥៩ | ១៣.៩២៤ | ៨.៧៣៩ | | | |
| | សរុប ក្រសួង ស្ថាប័ន | ១៥៩ លើក | ១៣.៩២៤ នាក់ | ៨.៧៣៩ នាក់ | | | |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៤៧ | ៥.១៧១ | ២.៥២០ | ៦៧២ | ២៣.៣៧៨ | ១១.៩៨៥ |
| ៣ | ខេត្តបាត់ដំបង | ៥៨២ | ៣៧.២៣៣ | ១៩.៧៥២ | ៣០៦ | ១២.៤៦៦ | ៦.៧០៤ |
| ៤ | ខេត្តពោធិ៍សាត់ | ៤៤៩ | ២៦.៩៦៨ | ១៧.០០៣ | ១៣៤ | ៥.០៨៧ | ២.៥០៤ |
| ៥ | ខេត្តសៀមរាប | ១.៦៤៣ | ២៣.២២២ | ១៥.១៩៩ | ៨៨ | ៤.៥១៤ | ២.៧៨៤ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៦៦០ | ៤០.១១៣ | ១៩.៤៤០ | ៤៤៧ | ១៩.៦០២ | ១០.៨០៤ |
| ៧ | ខេត្តកំពង់ចាម | ២៥៨ | ១៥.៨៦០ | ៨.៩៧១ | ៤១៦ | ២០.២៦២ | ១១.៤៣៥ |
| ៨ | ខេត្តព្រះសីហនុ | ១៤ | ៨៩២ | ៤៩៦ | | | |
| ៩ | ខេត្តព្រះវិហារ | ១២ | ៣.២៥៩ | ១.៦៨៦ | ០៦ | ២.៦០៥ | ១.៣៧៦ |
| ១០ | ខេត្តស្វាយរៀង | ០១ | ២៣ | ០២ | ៣៣៩ | ១២.៣២៦ | ៩.៩១២ |
| ១១ | ខេត្តប៉ៃលិន | | | | | | |
| ១២ | ខេត្តកោះកុង | ០៤ | ២៨១ | ១៥១ | ៣៥ | ១.០៨០ | ៦១៨ |
| ១៣ | ខេត្តកំពត | ០៤ | ២៦ | ១៤ | | | |
| ១៤ | ខេត្តកំពង់ធំ | | | | | | |
| ១៥ | ខេត្តតាកែវ | ១៨៣ | ១៦.៦៤៧ | ៨.០៤១ | ៣១ | ១.០៤១ | ៤២១ |
| ១៦ | ខេត្តក្រចេះ | ០១ | ៤៣ | ១៧ | | | |
| ១៧ | ខេត្តកែប | ១៤ | ៤.១៦៣ | ២.២៣០ | ១៥ | ៤.៩៣២ | ២.៥០៥ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | ០៣ | ២៤៧ | ១៣៥ | ០៤ | ២៩៥ | ១៧៩ |
| ២០ | ខេត្តរតនគិរី | ១៩ | ៩១៣ | ៤៧០ | ២០ | ១.២៦០ | ៦៣៦ |
| ២១ | ខេត្តព្រៃវែង | | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ៥ | ១២០ | ០ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| | សរុប រាជធានី-ខេត្ត | ៣.៨៩៩ លើក | ១៧៥.១៨១ នាក់ | ៩៦.១២៧ នាក់ | ២.៥១៣ លើក | ១០៨.៨៤៨ នាក់ | ៦១.៨៦៣ នាក់ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ៦.៥៧១ លើក | | ចំនួនមនុស្សសរុប ២៩៧.៩៥៣ នាក់ | | ចំនួនស្ត្រី ១៦៦.៧២៩ នាក់ | |

### ខ.១.២.ការផ្សព្វផ្សាយតាមរយៈឧបករណ៍ ប្រព័ន្ធផ្សព្វផ្សាយ និងការចូលរួមជាវ៉ាគ្និន

#### ខ.១.២.១.ការផ្សព្វផ្សាយតាមរយៈឧបករណ៍ផ្សព្វផ្សាយ និងតាមប្រព័ន្ធផ្សព្វផ្សាយ

- ខេត្តសៀមរាបៈ

មន្ទីរព័ត៌មានខេត្ត បានសហការជាមួយអង្គភាព អាជ្ញាធរ និងអង្គការពាក់ព័ន្ធ ចូលរួមជាវ៉ាគ្និន ដើម្បីផលិតកម្មវិធីយើងធ្វើបាន និងកម្មវិធីសន្ទនាមតិ "នាទីស្រុកយើង" ដើម្បីឲ្យយល់ដឹងពីអំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរ

មនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយធ្វើការផ្សាយផ្ទាល់ និងចាក់ផ្សាយឡើងវិញនៅវិទ្យុFM ជាតិនគរភ្នំ១០៣MHZ ទូរទស្សន៍ជាតិខេត្តសៀមរាប (ទូរទស្សន៍ខ្មែរកាបអង្គរខេត្តសៀមរាប ប៉ុស្តិ៍លេខ៩៥) និងតាមប្រព័ន្ធអនឡាញ សរុបបានចំនួន ៣៩លើក (ផ្សាយផ្ទាល់ ១០លើក ចាក់ផ្សាយឡើងវិញ ២៩លើក)។

ខ.១.២.២.ការចូលរួមជាវាគ្មិន

- ខេត្តបាត់ដំបង៖

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមធ្វើបទបង្ហាញអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព រៀបចំដោយអង្គការការីតាសកម្ពុជា អ្នកចូលរួមចំនួន ២១នាក់ (ស្រី ១២នាក់) នៅសាលាស្រុកភ្នំព្រឹក។

## ខ.២. ការបង្ការ ទប់ស្កាត់ តាមរយៈវិធានការជំនាញ

### ខ.២.១.វិធានការជំនាញទប់ស្កាត់ការធ្វើទេសន្តរប្រវេសន៍ (ចំណាកស្រុក)

ខ.២.១.១.ការគ្រប់គ្រងជនបរទេស

- អគ្គនាយកដ្ឋានអន្តោប្រវេសន៍

១. ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់: ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា សរុបចំនួន ១១៣លើក មនុស្សចំនួន ១៣០នាក់(ស្រី ០៧នាក់) មាន ៤២សញ្ជាតិ ត្រូវបានបណ្តេញចេញដោយ៖

- ប្រកាសក្រសួងមហាផ្ទៃ ៣៦លើក មនុស្សចំនួន ៤៨នាក់ (ស្រី ០៧នាក់) មាន ១៦សញ្ជាតិ។
- បដិសេធមិនឲ្យចូលប្រទេស តាមប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ ៧៧លើក មនុស្សចំនួន ៨២នាក់ ២៦សញ្ជាតិ។

២. ករណីស្នាក់នៅខុសច្បាប់

- គ្មានឯកសារគ្រប់គ្រាន់ ០៤លើក មនុស្សចំនួន ០៤នាក់ សញ្ជាតិរុស្ស៊ី អាហ្វ្រិកខាងត្បូង អូស្ត្រាលី និងស្កុតឡែន។
- ហួសទិដ្ឋាការស្នាក់នៅ ០១លើក មនុស្សចំនួន ០១នាក់ សញ្ជាតិថៃ។
- គ្មានលិខិតស្នាម ០១លើក មនុស្សចំនួន ០២នាក់ សញ្ជាតិចិន។
- គ្មានលិខិតឆ្លងដែន ០៣លើក មនុស្សចំនួន ០៩នាក់ សញ្ជាតិវៀតណាម។

៣. ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី

- ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ពីជនបរទេសបែបអន្តោប្រវេសន៍ សរុបមនុស្សចំនួន ១៤២នាក់ (ស្រី ៦៤នាក់) ៧២គ្រួសារ សញ្ជាតិវៀតណាម ក្នុងនោះដកហូតឯកសារ បានចំនួន ១៣១ឯកសារ។

ខ.២.១.២.ការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក

- អគ្គស្នងការដ្ឋាននគរបាលជាតិ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានធ្វើបច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស សរុបចំនួន ៣៥២.៥៣០នាក់ (ស្រី ១៨៤.៥៩៨នាក់) អនីតិជន ៨.៦៤១នាក់ (ស្រី ៣.៤២៥នាក់) ក្នុងនោះស្របច្បាប់ចំនួន

២០៧.៧២៥នាក់ (ស្រី ១២០.០៥៨នាក់) អនីតិជន ១.៩៩៥នាក់ (ស្រី ៨៧២នាក់) មិនស្របច្បាប់ ចំនួន ១៤៤.៨០៥នាក់ (ស្រី ៦៤.៥៤០នាក់) អនីតិជន ៦.៦៤៦នាក់ (ស្រី ២.៥៥៣នាក់) បើប្រៀបធៀបនឹងខែមីនាមានការកើនចំនួន ៦៥៥នាក់ ស្មើ 0,១៨%។

- **ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរៈសេនាតូចការពារព្រំដែនគោកលេខ ៨១៧ ៨១៩ ៨២៣ និង៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនដើម្បីទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ ចំនួន ៤១លើក ពុំប្រទះឃើញពលករឆ្លងដែនខុសច្បាប់ទេ។
- **ស្នងការដ្ឋាននគរបាលខេត្តរតនគិរី៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរៈនគរបាលការពារព្រំដែនគោក បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួន ចំនួន ០៩លើក (ព្រំដែនកម្ពុជា-វៀតណាម ៥៣លើក និងព្រំដែនកម្ពុជា-ឡាវ ០៤លើក)។

**ខ.២.២.វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ**

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
  - **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ សរុបចំនួន ៧៥គោលដៅ ក្នុងនោះអំពើជួញដូរមនុស្សចំនួន ០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន ៦៦គោលដៅ។
  - **ស្នងការដ្ឋាននគរបាលខេត្ត** ធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ស្ត្រីក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន ៤៤៣គោលដៅ និងមានមនុស្សចំនួន ២.៣៤៣នាក់ (ស្រី ១.៩២៧នាក់) នៅខេត្តតាកែវ មណ្ឌលគិរី ស្វាយរៀង សៀមរាប កែប ក្រចេះ និងខេត្តបន្ទាយមានជ័យ។
  - **ស្នងការដ្ឋាននគរបាលខេត្ត** ល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន ២២លើក នៅខេត្តស្វាយរៀង ស្ទឹងត្រែង កំពង់ស្ពឺ ក្រចេះ និងខេត្តព្រៃវែង។

**ខ.២.៣.ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) នៃច្រកចេញចូលតែមួយ របស់ក្រសួងមហាផ្ទៃទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសសរុបចំនួន ១១៩គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនង ទៅនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីនៅក្រៅប្រទេស តាមរយៈទូរស័ព្ទផ្ទាល់ ចំនួន ១២នាក់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្ស តាមរយៈការរៀបអាពាហ៍ពិពាហ៍។

## ខ.៣. កិច្ចការពារកុមារ

- **ខេត្តប៉ៃលិន៖**

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ច ដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសែឡូ កាស៊ីណូ ឡឥដ្ឋ ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន ៨០កន្លែង។

- ខេត្តស្វាយរៀង៖

បានចុះស្រង់ទិន្នន័យតាមគោលដៅសិប្បកម្ម សង្ស័យអាចពាក់ព័ន្ធការកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារ ចំនួន ០៤លើក ស្មើនឹង ១៨គោលដៅ ដោយបានធ្វើការណែនាំ និងធ្វើកិច្ចសន្យាដល់ម្ចាស់សិប្បកម្មផងដែរ។

- ខេត្តសៀមរាប៖
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះអធិការកិច្ចពលកម្មកុមារ នៅក្នុងវិស័យឡឥដ្ឋ ចំនួន ០៣លើក នៅស្រុកសូទ្រនិគម ស្រុកបន្ទាយស្រី និងស្រុកអង្គរជុំ ដោយក្រុមការងារបានចែកជូនសេចក្តីប្រកាសព័ត៌មាន ស្តីពីករណីគ្រោះថ្នាក់ក្នុងសិប្បកម្មផលិតឥដ្ឋ និងផ្សព្វផ្សាយផលប៉ះពាល់ នៃទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងបានពិនិត្យទៅលើបច្ចេកទេស និងការប្រើប្រាស់កម្លាំងពលកម្ម (ពិសេសពលកម្មកុមារ) បន្ទាប់មកបានធ្វើការណែនាំដល់ម្ចាស់សហគ្រាសឲ្យមានការប្រុងប្រយ័ត្នចំពោះកុមារដែលធ្វើការនៅក្នុងទីតាំងឡឥដ្ឋរបស់ខ្លួន។

**ខ.៤. ការកាត់បន្ថយភាពងាយរងគ្រោះ តាមរយៈការផ្តល់ប័ណ្ណព្រំដែនដល់មុខសញ្ញាងាយរងគ្រោះ**

- រដ្ឋបាលខេត្តចំនួន០៣ គឺខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass) សរុបចំនួន ៩.២១៨ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មាន៖
  - ខេត្តបាត់ដំបង ចំនួន ៦.៦៤៣ប័ណ្ណ
  - ខេត្តបន្ទាយមានជ័យ ចំនួន ១.៤៥៤ប័ណ្ណ
  - ខេត្តប៉ៃលិន ចំនួន ១.១២១ប័ណ្ណ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង កណ្តាល ព្រៃវែង សៀមរាប ស្ទឹងត្រែង ស្វាយរៀង តាកែវ និងខេត្តប៉ៃលិន។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន ១១ករណីលើ១៩ករណី (បើប្រៀបធៀបនឹងខែមីនា គឺមានការថយចុះចំនួន ០៨ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ១៥នាក់(ស្រី ០៥នាក់ អនីតិជន ០១នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ៣០នាក់ មានអាយុក្រោម១៥ឆ្នាំ ០៧នាក់ និងអាយុ១៨ឆ្នាំឡើង ២៣នាក់(ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ០៧នាក់ និងប្រគល់ទៅគ្រួសារ ២៣នាក់) ក្នុងនោះមាន៖

##### គ.១.១.១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០១ករណីលើ០១ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ០៥នាក់ មានអាយុ១៨ឆ្នាំឡើង ០៥នាក់ (ប្រគល់ទៅគ្រួសារទាំងអស់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -អំពើនាំឆ្លងដែន | ០១ | ០៥ | ០១ |
| *សរុប* | *០១ ករណី* | *០៥ នាក់* | *០១ នាក់* |

គ.១.១.២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១០ករណីលើ១៨ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១៤នាក់(ស្រី ០៥នាក់ អនីតិជន ០១នាក់) សង្គ្រោះជនរងគ្រោះចំនួន ២៥នាក់ មានអាយុក្រោម១៥ឆ្នាំ ០៧នាក់ និងអាយុ១៨ឆ្នាំឡើង ១៨នាក់(ប្រគល់ទៅមន្ទីរសង្គមកិច្ច ០៧នាក់ និងប្រគល់ទៅគ្រួសារ ១៨នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -សញ្ចារកម្ម | ០១ | ០៥ | ០១ |
| -ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ០២ | ១៣ | ០៦ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៦ | ០៦ | ០៦ (អនី.១) |
| -អំពើអាសប្រងាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ | ០១ |
| *សរុប* | *១០ ករណី* | *២៥ នាក់* | *១៤ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

  យោងស្ថិតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនពលរដ្ឋខ្មែរសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការដៃគូ សរុបចំនួន ០៦នាក់ ក្នុងនោះមកពី៖

  - ប្រទេសចិន ចំនួន ០៣នាក់
  - ប្រទេសម៉ាឡេស៊ី ចំនួន ០២នាក់
  - ប្រទេសឥណ្ឌូនេស៊ី ចំនួន ០១នាក់។

- អគ្គស្នងការដ្ឋាននគរបាលជាតិ

  នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសពលករខ្មែររងគ្រោះចំនួន ១៥នាក់(ស្រី ១២នាក់) ដែលត្រឡប់ពីប្រទេសចិន ១១នាក់ ឥណ្ឌូនេស៊ី ០៣នាក់ និងម៉ាឡេស៊ី ០១នាក់។ តាមការសម្ភាសបានឲ្យដឹងថាទៅតាមរយៈមេខ្យល់ ១២នាក់។

- អគ្គនាយកដ្ឋានអន្តោប្រវេសន៍

  បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ១២៦លើក មនុស្សចំនួន ១.៦៣៨នាក់(ស្រី ៥៥១នាក់ កុមារ ១៣៥នាក់)។ ក្នុងនោះតាម៖

- ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ៤៧លើក មនុស្សចំនួន ១០៧នាក់ (ស្រី ៤០នាក់)
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ៧៩លើក មនុស្សចំនួន ១.៥៣១នាក់ (ស្រី ៥១១នាក់ កុមារ ១៣៥នាក់)។

▪ **អគ្គបញ្ជាការដ្ឋាន ទីចាត់ការការងារព្រំដែន**

បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ សរុបចំនួន ១.៥០១នាក់(ស្រី ៥១៩នាក់ អនីតិជន ១៨២នាក់) ក្នុងនោះមាន៖

- ច្រកអន្តរជាតិប៉ោយប៉ែត ចំនួន ១.៣២៤នាក់ (ស្រី ៤៦២នាក់) អនីតិជន ១៧៩នាក់
- ច្រកអន្តរជាតិដូង ចំនួន ១៧១នាក់ (ស្រី ៥៧នាក់) អនីតិជន ០៣នាក់
- ច្រកអន្តរជាតិជាំ ចំនួន ០៦នាក់។

• **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

**ស្នងការដ្ឋាន**នគរបាលខេត្ត ចំនួន៤ បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងតាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម សរុបចំនួន ១.៣០៩នាក់(ស្រី ៤៣៥នាក់ អនីតិជន ១៣៩នាក់) ក្នុងនោះមាន៖

- **ខេត្តបន្ទាយមានជ័យ** ចំនួន ១.០៦៦នាក់ (ស្រី ៣៤៩នាក់) អនីតិជន ១៣២នាក់
- **ខេត្តបាត់ដំបង** ចំនួន ២០៥នាក់ (ស្រី ៦៩នាក់)
- **ខេត្តកោះកុង** ចំនួន ២៣នាក់ (ស្រី ០៤នាក់)
- **ខេត្តស្វាយរៀង** ចំនួន ១៥នាក់ (ស្រី ១៣នាក់) អនីតិជន ០៧នាក់។

**ឃ.១.២. ការទទួលសាកសពបញ្ជូនត្រឡប់**

▪ **អគ្គបញ្ជាការដ្ឋាន ទីចាត់ការការងារព្រំដែន**

បានទទួលសាកសពដែលអាជ្ញាធរថៃបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែនអន្តរជាតិដូង ចំនួន ០៩សព (ស្រី ០៣)។

## ឃ.២. ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទាចំនួន ៣៧នាក់(ស្ត្រី ១០នាក់ កុមារ ១៩នាក់) រួមមាន៖

- មជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានផ្តល់សេវាស្នាក់នៅរយៈពេលខ្លី និងស្តារនីតិសម្បទា ដល់ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ៣២នាក់(ស្ត្រី ១០នាក់ កុមារ ១៩នាក់) និងបានបញ្ជូនទៅអង្គការគ្រួសារថ្មី អង្គការតំណក់ទឹក អង្គការក្តីសង្ឃឹមនិងយុត្តិធម៌ អង្គការក្តីសង្ឃឹមពិភពលោក ដើម្បីទទួលសេវាអប់រំក្នុង និងក្រៅប្រព័ន្ធ និងសេវាផ្សេងៗទៀតមុនពេលធ្វើសមាហរណកម្មត្រឡប់ទៅផ្ទះវិញ។
- មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ បានសហការទទួលនារីរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ០៥នាក់ ធ្វើការពិគ្រោះយោបល់ និងបញ្ជូនទៅសេវាបន្តនៅអង្គការដៃគូ។

### ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងខាយរងគ្រោះ

- បានធ្វើសមាហរណកម្មស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រឡប់ទៅសហគមន៍វិញចំនួន ០៣នាក់ (ករណីរងគ្រោះដោយការជួញដូរកម្លាំងពលកម្ម ០១នាក់ និងអាជីវកម្មផ្លូវភេទ ០២នាក់)។
- មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ បានធ្វើសមាហរណកម្មកុមារីរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ០១នាក់ ត្រឡប់ទៅសហគមន៍វិញ។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

តារាងវគ្គបណ្តុះបណ្តាល

| ល.រ | សកម្មភាព | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | ខេត្តពោធិ៍សាត់៖ មន្ទីរកិច្ចការនារីខេត្ត បានបើកវគ្គបណ្តុះបណ្តាលថ្នាក់ភូមិ ស្តីពីការបញ្ច្រាបយេនឌ័រ ការធ្វើចំណាកស្រុកដោយដោយសុវត្ថិភាព ព្រមទាំងច្បាប់ជួញដូរមនុស្ស ដល់ មេភូមិ អនុភូមិ និងសមាជិកភូមិ នៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ | ០១ | ២៥ | ០៥ |
| | សរុប | ០១ វគ្គ | ២៥ នាក់ | ០៥ នាក់ |

#### ក.២. សិក្ខាសាលា

ក.២.១.សិក្ខាសាលាក្នុងប្រទេស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)៖

  បានសហការជាមួយអង្គការ Plan Inernationnal និងអង្គការ Cambodia Act រៀបចំសិក្ខាសាលាពិនិត្យលើសេចក្តីសម្រេច នៃការសិក្សាអំពីសេវាការពារសង្គម ដើម្បីលើកកម្ពស់ការឆ្លើយតបទៅនឹងការប៉ះពាល់លើកុមារ ក្នុងទេសន្តរប្រវេសន៍ ដែលមានសិក្ខាកាមចូលរួមចំនួន ៥៧នាក់ (ស្រី ២៤នាក់) នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។

- ខេត្តប៉ៃលិន៖

  មន្ទីរទេសចរណ៍ខេត្ត បានរៀបចំសិក្ខាសាលា ស្តីពីសុវត្ថិភាពកុមារ និងបានបញ្ច្រាបការធ្វើចំណាកស្រុកដោយស្របច្បាប់ក្នុងវិស័យទេសចរណ៍ សិក្ខាកាមចូលរួមចំនួន ៨០នាក់ (ស្រី ៤០នាក់)។

### ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

#### ខ.១ សន្និសីទថ្នាក់ជាតិ និងអន្តរជាតិ

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)

  លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជាអធិបតីភាពបើកអង្គសន្និសីទអន្តរជាតិកិច្ចសហប្រតិបត្តិការទ្វេភាគីលើកទី២ កម្ពុជា-ថៃ ស្តីពីទេសន្តរប្រវេសន៍ការងារ និងអំពើជួញដូរមនុស្ស ដែលមានការចូលរួមពីតំណាងមន្ទីរការងារប្រទេសថៃ តំណាងភាគីកម្ពុជា អាជ្ញាធរមានសមត្ថកិច្ច ប្រតិភូសហភាពអឺរ៉ុប ទីភ្នាក់ងារអង្គការសហប្រជាជាតិ តំណាងអង្គការសង្គមស៊ីវិល វិស័យឯកជន សរុបអ្នកចូលរួមប្រមាណ ៧០នាក់ នៅសណ្ឋាគារ AngKor Miracle ខេត្តសៀមរាប។

## ខ.២. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

➢ កិច្ចប្រជុំក្នុងប្រទេស

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)

- **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ថ្នាក់ជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៨ និងលើកទិសដៅអនុវត្ត ឆ្នាំ២០១៩ ដែលមានអ្នកចូលរួមចំនួន ៣៦៩នាក់ (ស្រី ១១៩នាក់) នៅទីស្តីការក្រសួងមហាផ្ទៃ។
- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវអំពីសេវាសង្គម ដើម្បីលើកកម្ពស់ការឆ្លើយតបទៅនឹងផលប៉ះពាល់លើកុមារក្នុងទេសន្តរប្រវេសន៍ អ្នកចូលរួមចំនួន ២៨នាក់ (ស្រី ០៧នាក់) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

➢ កិច្ចប្រជុំក្រៅប្រទេស

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)

ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដឹកនាំគណៈប្រតិភូព្រះរាជាណាចក្រកម្ពុជា សរុបចំនួន ២៥នាក់ (ស្រី ០៧នាក់) តំណាងមកពីៈ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃ អង្គការ IOM និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីទៅចូលរួមកិច្ចប្រជុំ ស្តីពីពិធីចុះហត្ថលេខាលើនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីដំណើរការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅទីក្រុងបាងកក ប្រទេសថៃ។

## ខ.៣. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៣៤លើក មានអ្នកចូលរួមសរុប ៤២៥នាក់ (ស្រី ២០០នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ០៨លើក ក្រសួងសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទា ០១លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ២៥លើក។ (ឧបសម្ព័ន្ធ១)

# III. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.ខ.ប.ជ/គ.រ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។

- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## IV. ទិសដៅខែឧសភា ឆ្នាំ ២០១៩

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដេកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ **"គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី"** (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ..................ខែ...........ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៩

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជុំ ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៣៤លើក) មនុស្សចំនួន ៤២៥នាក់ (ស្រី ២០០នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | សម្របសម្រួលចំនួន ០៨លើក អ្នកចូលរួមចំនួន ៨៥នាក់ ស្រី ១០នាក់<br>▪ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំមន្ត្រីជាន់ខ្ពស់នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះពិនិត្យ និងស្វែងយល់ពីបទពិសោធន៍ការងារ និងភាពប្រឈមក្នុងរយៈពេលកន្លងមក ដើម្បីរកវិធានការដោះស្រាយ ពីក្រុមការងារចម្រុះទទួលពលករ ប្រកអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។<br>▪ **លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>- បិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំ ឆ្នាំ២០១៨ និងលើកទិសដៅអនុវត្ត ឆ្នាំ២០១៩ របស់ក្រសួងកិច្ចការនារី នៅសណ្ឋាគារភ្នំពេញ។<br>- កិច្ចប្រជុំ ស្តីពីពិធីចុះហត្ថលេខាលើនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីដំណើរការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសណ្ឋាគារកាំបូឌីយ៉ាណា។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១៥ច្បាប់ លិខិតចូល ១៦ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១៦ច្បាប់ លិខិតចូល ០៧ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែមេសា ឆ្នាំ២០១៩ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ខែមេសា ឆ្នាំ២០១៩ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី។<br>- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។<br>- Scan & Uploaded ឯកសារចូលក្នុងបណ្ណាសារនៃប្រព័ន្ធ wiki បានចំនួន ១៧ច្បាប់។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ឧ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធអ៊ិនធើណេត wiki បានចំនួន ១៧សកម្មភាព។<br>▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ៖**<br>- បានជួបសំណេះសំណាល និងផ្តាំផ្ញើដល់ស្ត្រីពពោះជំនួសចំនួន ០៧នាក់ ក្នុងចំណោម ១១នាក់ ដែលត្រូវតុលាការដោះលែងឲ្យនៅក្រៅឃុំ តែក្នុងនោះមាន ០៣នាក់ទៅមុន និង ០១នាក់ទៀត ពុំទាន់ចេញដោយមូលហេតុ គាត់មិនត្រូវការអន្តរាគមន៍ពីខាងអង្គការ AIM ដោយមូលហេតុគាត់មានមេធាវីរបស់គាត់ហើយ។ |

| | |
|---|---|
| | - ប្រជុំឆ្លងផែនការយុទ្ធសាស្ត្រទី៤ ស្ដីពីការលើកកម្ពស់កិច្ចការពារជនរងគ្រោះជាពិសេសស្ត្រី និងកុមារ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>▪ **ក្រុមជំនួយការយុត្តិធម៌៖**<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **យឹម វិរៈ** បានអញ្ជើញចូលរួម៖<br>○ ប្រជុំឆ្លងសេចក្ដីព្រាងអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីកិច្ចសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃស៊ែប៊ី និងក្រសួងមហាផ្ទៃកម្ពុជា នៅទីស្ដីការក្រសួងមហាផ្ទៃ។<br>○ សិក្ខាសាលាពិគ្រោះយោបល់ដើម្បីពិនិត្យ និងសម្រេចលើសេចក្ដីព្រាងសារអប់រំ ស្ដីពីការការពារកុមារពីការរំលោភបំពាន និងបៀតបៀនផ្លូវភេទ រៀបចំដោយក្រុមប្រឹក្សាជាតិដើម្បីកុមារ អ្នកចូលរួមចំនួន ៦០នាក់ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>○ សិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងគោលនយោបាយជាតិ ស្ដីពីប្រព័ន្ធកិច្ចការពារកុមារ រៀបចំដោយក្រុមប្រឹក្សាជាតិដើម្បីកុមារ នៅកោះជនីយដ្ឋានទន្លេបាសាក់១ រាជធានីភ្នំពេញ។<br>- អនុប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ បានចូលរួមសន្និបាទបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នៅទីស្ដីការក្រសួងមហាផ្ទៃ។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ៖**<br>- លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា**<br>○ បានដឹកនាំមន្ត្រីក្រុមការងារបច្ចេកទេសគ្រប់គ្រងព័ត៌មានវិទ្យា នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះទៅមណ្ឌលសំចតពលករប៉ោយប៉ែត ដើម្បីធ្វើបច្ចុប្បន្នភាពការងារទាក់ទងនឹងប្រព័ន្ធគ្រប់គ្រងពលករ និងធ្វើការដោះស្រាយទៅលើបញ្ហាប្រឈមផ្សេងៗ។<br>○ បានដឹកនាំមន្ត្រីក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ប្រជុំជាមួយក្រុមការងារខេមមីតកម្ពុជា ដែលដឹកនាំដោយលោកជំទាវ ហ៊ូ សាមិត្ត រដ្ឋលេខាធិការក្រសួងកិច្ចការនារី អ្នកចូលរួមចំនួន ២៥នាក់ ស្រី ១០នាក់ នៅទីស្ដីការក្រសួងកិច្ចការនារី។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | - បានរៀបចំកិច្ចប្រជុំ ស្ដីពីការធ្វើបច្ចុប្បន្នភាពទម្រង់ទទួលជនរងគ្រោះ ដែលត្រូវធ្វើសមាហរណកម្ម និងស្វែងរកគ្រួសារ (ទម្រង់ទាំង៧កម្មវិធីសមាហរណកម្ម) ដឹកនាំកិច្ចប្រជុំដោយ ឯកឧត្តម តូច ចាន់នី អគ្គនាយកបច្ចេកទេស អ្នកចូលរួមចំនួន ២៥នាក់ ស្រី១៥នាក់។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ២៥លើក អ្នកចូលរួមសរុបចំនួន ៣១៥នាក់ (ស្រី ១៧៥នាក់)** | |
| **ខេត្តព្រះសីហនុ** | - លោកជំទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រីមាសទី១ ឆ្នាំ២០១៩ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត អ្នកចូលរួមចំនួន ៥៧នាក់ ស្រី ២២នាក់។ |
| **ខេត្តកោះកុង** | - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅទីស្ដីការក្រសួងមហាផ្ទៃ។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាស១ និងប្រចាំមីនា ឆ្នាំ២០១៩ និងទិសដៅបន្ត អ្នកចូលរួមចំនួន ៣៧នាក់ ស្រី ១៣នាក់។ |
| **ខេត្តតាកែវ** | - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅទីស្ដីការក្រសួងមហាផ្ទៃ។ |

| | |
|---|---|
| **ខេត្តកំពង់ស្ពឺ** | - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាស១ ឆ្នាំ២០១៩ អ្នកចូលរួមចំនួន ៥៤នាក់ ស្រី ២៧នាក់។ |
| **ខេត្តកំពង់ឆ្នាំង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យការងារប្រចាំខែមេសា ឆ្នាំ២០១៩ ដែលមានសមាសភាពក្រុមទាំង៦ និងស្រុក-ក្រុង ទាំង៨។ |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត ក្រុមការងារក្រុង-ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែចំនួន ០៨លើក អ្នកចូលរួមចំនួន ១៦៧នាក់ ស្រី ១១៣នាក់។ |
| **ខេត្តកំពង់ធំ** | - លោកជំទាវប្រធានលេខាធិការដ្ឋានគ.ខ.ប.ជខេត្ត បានអញ្ជើញចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចាត់មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលះ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងការជួញដូរមនុស្ស នៅសណ្ឋាគារសោម៉ាវត្តី។ និងបំប៉នជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៅបណ្ឌិត្យសភានគរបាលកម្ពុជា។ |
| **ខេត្តសៀមរាប** | លោកជំទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានអញ្ជើញចូលរួមៈ<br>- កិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- សន្និសីទអន្តរជាតិ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីលើការងារទេសន្តរប្រវេសន៍ការងារ និងអំពើជួញដូរមនុស្សលើកទី២ រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃឡង់ដ៏ នៅសណ្ឋាគារអេង្គរមីរ៉ាខល ខេត្តសៀមរាប។<br>- សិក្ខាសាលា ពិនិត្យសម្រេចលើលទ្ធផលនៃការសិក្សាអំពីសេវាសង្គម ដើម្បីលើកកម្ពស់ការឆ្លើយតបទៅនឹងផលប៉ះពាល់លើកុមារក្នុងទេសន្តរប្រវេសន៍ នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។ |
| **ខេត្តព្រៃវែង** | លោកជំទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានអញ្ជើញចូលរួមៈ<br>- កិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- សិក្ខាសាលា ពិនិត្យសម្រេចលើលទ្ធផលនៃការសិក្សាអំពីសេវាសង្គម ដើម្បីលើកកម្ពស់ការឆ្លើយតបទៅនឹងផលប៉ះពាល់លើកុមារក្នុងទេសន្តរប្រវេសន៍ នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។ |
| **ខេត្តស្វាយរៀង** | - បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំត្រីមាសទី១ និងទិសដៅបន្ត ឆ្នាំ២០១៩ អ្នកចូលរួមចំនួន ៤៧នាក់ ស្រី២៨នាក់។ |
| **ខេត្តបាត់ដំបង** | - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។ |
| **ខេត្តប៉ៃលិន** | - លោកជំទាវអភិបាលរងខេត្ត បានអញ្ជើញជួបប្រជុំជាមួយមន្ត្រីជំនាញនៅច្រកទ្វារព្រំដែនអន្តរជាតិព្រំ ដើម្បីត្រៀមសម្របសម្រួលដល់ពលករខ្មែរ ដែលចេញចូលឆ្លងដែនមកលេងស្រុកកំណើតក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។ |